ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ធំ
*********

**សាលក្រមព្រហ្មទណ្ឌ**
លេខ: ២២ "ច"
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ: ២៥១
ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣
**សំណុំរឿងស៊ើបសួរ**
លេខ: ១៤៨
ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣
**សំណុំរឿងជំនុំជម្រះ**
លេខ: ៤៩៣
ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ធំ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤
វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក នៅសាលសវនាការខេត្តកំពង់ធំ
ដោយមានសមាសភាពដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ជាចៅក្រមជំនុំជម្រះ

**តំណាងអយ្យការ**

-លោក [redacted] ជាតំណាងអយ្យការ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ជាក្រឡាបញ្ជី

**មេធាវី**

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ
-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ២៥១ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

**១**-ឈ្មោះ [redacted] **ម៉ុំ** ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នរស់នៅភូ[redacted] ខេត្តកំពង់ធំ កម្រិតវប្បធម៌៖ អត់ចេះអក្សរ ឪពុកឈ្មោះ [redacted] ផុន (ស្លាប់) ម្តាយឈ្មោះ [redacted] មន្នី (រស់) ប្តីឈ្មោះ [redacted] **អូន** (រស់) មានកូនចំនួន០១ នាក់ ជានីតិជន ទោសពីមុន៖ គ្មាន។ (ក្រៅឃុំ)

**២**-ឈ្មោះ [redacted] **ភាព** ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើត[redacted] ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្នរស់នៅភូ[redacted] ខេត្តកំពង់ធំ កម្រិតវប្បធម៌៖ថ្នាក់ទី៥ ឪពុកឈ្មោះ [redacted] ម៉ែត (ស្លាប់) ម្តាយឈ្មោះ [redacted] សែ (រស់) ប្រពន្ធឈ្មោះ [redacted] **គីមអៀង** (រស់) មានកូនចំនួន០៤នាក់ ជានីតិជន ទោសពីមុន៖ គ្មាន។ (ក្រៅឃុំ)

**៣**-ឈ្មោះ [redacted] **អូន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូ[redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ[redacted] ខេត្តកំពង់ធំ កម្រិតវប្បធម៌៖ អត់បានរៀនទេ ឪពុកឈ្មោះ [redacted] ឡាយ (ស្លាប់) ម្តាយឈ្មោះ [redacted] ហៀប (ស្លាប់) ប្រពន្ធឈ្មោះ [redacted] ម៉ុំ (រស់) មានកូនចំនួន០១នាក់ ជានីតិជន ទោសពីមុន៖ គ្មាន។ (ក្រៅឃុំ)

**៤**-ឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរ កសិករ មានទីកន្លែងកំណើតភូមិ[redacted] ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ[redacted] ខេត្តកំពង់ធំ កម្រិតវប្បធម៌៖ថ្នាក់ទី០៦ ឪពុកឈ្មោះ [redacted] ឡាយ (ស្លាប់) ម្តាយឈ្មោះ [redacted] ហៀប (ស្លាប់) ប្តីឈ្មោះ [redacted] ភាព (រស់) មានកូនចំនួន០៤នាក់ ជានីតិជន ទោសពីមុន៖ គ្មាន។ (ក្រៅឃុំ)



Scanned with CamScanner

ជាប់ចោទពីបទ: "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**"ប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១**។

**ដើមបណ្តឹងរដ្ឋប្បវេណី**

-ឈ្មោះ [redacted] **សាអែម** ភេទស្រី អាយុ៣៣ឆ្នាំជាតិខ្មែរ រស់នៅភូមិត្រពាំងទឹម ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ ឈ្មោះ [redacted] សាអែម ភេទស្រី អាយុ៣៣ឆ្នាំ បានទិញដីចម្ការស្វាយកែវរមៀតមួយកន្លែងទំហំ ៤៤.៧៩០ ម៉ែត្រការ៉េ ស្ថិតនៅភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ពីឈ្មោះ [redacted] សុវណ្ណា ភេទស្រី អាយុ៤០ឆ្នាំ ដោយមានពាក្យសុំផ្ទេរសិទ្ធិដី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ និងលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២។ ក្រោយពីឈ្មោះ [redacted] សាអែម បានទិញដីចម្ការខាងលើរួចមក ឈ្មោះ [redacted] សាអែម និងប្តីឈ្មោះ [redacted] ទិត បាននាំគ្នាសម្អាតស្មៅ និងបាញ់ថ្នាំ ថែទាំដំណាំស្វាយនោះរហូតដល់បានផល។ ស្រាប់តែនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៣ ឈ្មោះ [redacted] អួន ភេទប្រុស អាយុ៥៩ឆ្នាំ ,ឈ្មោះ [redacted] មុំ ភេទស្រី អាយុ៦១ឆ្នាំ, ឈ្មោះ [redacted] ភាព ភេទប្រុស អាយុ៥៤ឆ្នាំ ,ឈ្មោះ [redacted] គីមអៀង ភេទស្រី អាយុ៥៣ឆ្នាំ និងបក្ខពួក បានមករារាំងឈ្មោះ [redacted] សាអែម និងប្តីឈ្មោះ [redacted] ទិត មិនឱ្យប្រមូលផលផ្លែស្វាយនេះទេ។ បន្ទាប់មកទៀត នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ឈ្មោះខាងលើបាននាំគ្នាទៅកាប់បំផ្លាញដំឡូងមីរបស់ដើមបណ្តឹងរដ្ឋប្បវេណីអស់មួយចំនួនធំ និងបានចូលទៅកាន់កាប់ដោយបានសង់រោង នៅលើដីនោះយកជាកម្មសិទ្ធិតែម្តង។ ជាងនេះទៀតឈ្មោះខាងលើបាននាំបក្ខពួករបស់ខ្លួនមកលួចបេះផ្លែស្វាយឈ្មោះ [redacted] សាអែម ថែមទៀត។

**បានឃើញ** ពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាអែម។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: **១៩០អ.ក/២០២៣** ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: **៤៧០/២០២៣** ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ។

**បានឃើញ** ដីកាដំណោះស្រាយលេខ: **៤១២០/២០២៣** ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ: **៦៥៦ ត.ប្រ** ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តកំពង់ធំ។

**នាពេលសវនាការ**

| | |
|---|---|
| -ជនជាប់ចោទឈ្មោះ [redacted] **មុំ** | **អវត្តមាន**។ |
| -ជនជាប់ចោទឈ្មោះ [redacted] **ភាព** | **វត្តមាន**។ |
| -ជនជាប់ចោទឈ្មោះ [redacted] **អួន** | **វត្តមាន**។ |
| -ជនជាប់ចោទឈ្មោះ [redacted] **គីមអៀង** | **វត្តមាន**។ |
| -ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាអែម** | **វត្តមាន**។ |
| -មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] | **វត្តមាន**។ |
| -មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] | **វត្តមាន**។ |
| -មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] | **វត្តមាន**។ |
| -មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] | **អវត្តមាន**។ |

**ដំណើរការសួរដេញដោលក្នុងពេលសវនាការ**

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **អួន** បានឆ្លើយនៅក្នុងដំណាក់កាលនៃនីតិវិធីថា៖ ខ្លួនសូមបដិសេធនៃខ្លឹមសារនៃពាក្យបណ្តឹងចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣ ទាំងស្រុងរបស់ឈ្មោះ [redacted] សាអែម។ ខ្លួនសូមបញ្ជាក់ថា: កាលពី

អំឡុងខែមេសា ឆ្នាំ២០២៣ ខ្លួនពិតជាបានប្រាប់ឱ្យឈ្មោះ [redacted] ភាព ដែលត្រូវជាប្អូនថ្លៃរបស់ខ្លួន និងកម្មករចំនួន ០៣ នាក់ទៀត ឱ្យទៅជួយធ្វើរោងនៅលើទីតាំងដីចម្ការមួយកន្លែងមានទីតាំងស្ថិតនៅភូមិភ្នំច្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ពិតប្រាកដមែន ដោយឱ្យតម្លៃឈ្នួលក្នុងម្នាក់ ៣០.០០០ (បីម៉ឺន) រៀល។ ចំពោះមូលហេតុ ដែលមានការចូលទៅកាន់កាប់ដីខាងលើ គឺដោយសារដីខាងលើនេះ គឺជាដីកេរ្តិ៍របស់ឪពុករបស់ខ្លួនឈ្មោះ [redacted] ឡាយ ជាមួយនឹងឈ្មោះ [redacted] សុវណ្ណា ដែលប្រពន្ធក្រោយរបស់គាត់ ហេតុដូចនេះ តាមផ្លូវច្បាប់ខ្លួនជាកូនក៏ត្រូវទទួលបានចំណែកលើដីនោះផងដែរ។ម្យ៉ាងវិញទៀត ក៏ដោយសារតែដីខាងលើ ពុំមានអ្នកថែទាំងជាប់លាប់ ហើយកន្លងមកក្រុមហ៊ុនចម្ការកៅស៊ូរបស់វៀតណាម ដែលមានទីតាំងស្ថិតនៅក្បែរដីខាងលើ ក៏បាននិយាយថា ប្រសិនបើមានភ្លើងឆេះចេញពីចម្ការខាងលើកើតឡើង នោះពួកគេនឹងប្តឹងចំពោះម្ចាស់ដីដែលគ្រប់គ្រងដីនោះ ដោយហេតុនេះហើយទើបខ្លួនសម្រេចចិត្តចូលទៅធ្វើរោងលើដីខាងលើតែម្តង។ ចំពោះការចូលទៅសង់រោងលើដីខាងលើ គឺខ្លួនក៏បានទៅសុំការអនុញ្ញាតពីមេភូមិនៅទីនោះផងដែរ ប៉ុន្តែគាត់ពុំបានចេញលិខិតជាលាយ លក្ខណ៍អក្សរឱ្យមកខ្លួននោះទេ គឺគាត់គ្រាន់តែអនុញ្ញាតដោយផ្ទាល់មាត់ប៉ុណ្ណោះ។ កន្លងលោកមេភូមិភ្នំច្រាច់ ក៏ធ្លាប់បានប្រាប់មកខ្លួនថា: ពេលចូលទៅកាន់កាប់ដីខាងលើ ត្រូវមើលថែដីនោះកុំឱ្យមានករណីភ្លើងឆេះជាយថាហេតុណាមួយកើតឡើង នាំឱ្យមានការប្តឹងផ្តល់គ្នាជាមួយក្រុមហ៊ុនកៅស៊ូដែលនៅក្បែរផងដែរ។ ក្រោយមកខ្លួនទៅពិនិត្យមើលដីខាងលើ ដើម្បីសង់រោងស្នាក់នៅក្នុងចម្ការខាងលើ ក៏មានដាំដើមដំឡូងមីជាច្រើនដើមផងដែរ។ ក្រៅពីនេះក៏មានដើមស្វាយជាច្រើនដើម ដែលឪពុកខ្លួនឈ្មោះ [redacted] ឡាយ បានដាំផងដែរ។ ហើយនៅពេលដែលសង់រោងខាងលើ គឺខ្លួនធ្វើរោងនៅលើដីដែលទំនេរប៉ុណ្ណោះ និងពុំបានធ្វើនៅលើដីដាំដំឡូងដូចការចោទប្រកាន់របស់ដើមបណ្តឹងនោះទេ ហើយក៏មិនបានទៅកាប់បំផ្លាញដើមដំឡូងមីទាំងនោះដែរ។ ខ្លួនសូមបញ្ជាក់ថា: នៅអំឡុងពេលដែលខ្លួនទៅកាន់កាប់ដីខាងលើនោះ ខ្លួនពុំបានដឹងថាដីខាងលើ ត្រូវបានឈ្មោះ [redacted] សុវណ្ណា លក់ទៅឱ្យឈ្មោះ [redacted] សារ៉ែម នោះឡើយ ពោលគឺក្រោយពេលមានទំនាស់លើដីខាងលើកើតឡើងប៉ុណ្ណោះ ទើបដឹងថា ដីខាងលើត្រូវបានឈ្មោះ [redacted] សុវណ្ណា បានលក់ទៅឱ្យឈ្មោះ [redacted] សារ៉ែម បាត់ទៅហើយ។ ខ្លួនសូមជម្រាបជូនថា: កន្លងទៅរូបខ្លួន និងបងប្អូនរបស់ខ្លួន ក៏ធ្លាប់មានការប្តឹងផ្តល់គ្នាទាក់ទងទៅនឹងការទាមទារដីមួយកន្លែងផ្សេងទៀត ក្រៅពីទីតាំងដីខាងលើជាមួយឈ្មោះ [redacted] សុវណ្ណា ដែលត្រូវជាប្រពន្ធក្រោយរបស់ឪពុកខ្លួនផងដែរ ហើយបណ្តឹងនោះបច្ចុប្បន្នកំពុងដំណើរការនៅសាលាឧទ្ធរណ៍នៅឡើយ។ ខ្លួនសូមបញ្ជាក់បន្ថែមទៀតថា ការចូលទៅកាន់កាប់ដីខាងលើនោះ គឺធ្វើឡើងក្នុងចេតនាដើម្បីមើលថែដីខាងលើក្នុងនាមជាសន្តតិកម្មស្របតាមច្បាប់ រួមទាំងការពារកុំឱ្យមានភ្លើងឆេះជាយថាហេតុណាមួយកើតឡើងប៉ុណ្ណោះ ពោលគឺប្រសិនបើខ្លួនបានដឹងថា ដីខាងលើត្រូវបានឈ្មោះ [redacted] សុវណ្ណា លក់ទៅឱ្យឈ្មោះ [redacted] សារ៉ែម រួចរាល់ហើយនោះ ខ្លួនក៏មិនទៅរវីរវល់ទៅនឹងដីខាងលើនោះដែរ។ ហើយចាប់ពីពេលនេះតទៅ ខ្លួននឹងមិនចូលទៅកាន់កាប់នៅលើដីនោះទៀតនោះទេ ហើយស្នើសុំរុះរើយករោង ដែលខ្លួនបានសង់នៅលើដីនោះមកវិញផងដែរ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ភាព** បានឆ្លើយនៅក្នុងដំណាក់កាលនៃនីតិវិធីថា៖ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ [redacted] អួន និងប្រពន្ធឈ្មោះ [redacted] មុំ (ដែលអ្នកទាំងពីរត្រូវជាបងថ្លៃរបស់ខ្លួន) ពិតជាបានជួលខ្លួន និងកម្មករចំនួន ០៣ នាក់ផ្សេងទៀត ឱ្យទៅជួយសង់រោងនៅក្នុងដីចម្ការរបស់គាត់មួយកន្លែង មានទីតាំងស្ថិតនៅក្នុងភ្នំច្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ប្រាកដមែន ដោយឱ្យតម្លៃឈ្នួលលើកម្មករម្នាក់ ចំនួន ៣០.០០០ (បីម៉ឺន) រៀល។ នៅមុនពេលចូលទៅធ្វើរោងនៅលើដីខាងលើ ខ្លួនក៏បានស្នើសុំឱ្យការអនុញ្ញាតពីមេភូមិនៅទីនោះផងដែរ ពីព្រោះខ្លាចមានបញ្ហា ប៉ុន្តែខាងមេភូមិពុំបានបានចេញលិខិតជាលាយលក្ខណ៍អក្សរនោះឡើយ ពោលគឺគ្រាន់តែអនុញ្ញាតឱ្យខ្លួនចូលទៅទីតាំងដីខាងលើដោយផ្ទាល់មាត់ប៉ុណ្ណោះ។ នៅអំឡុងពេលចូលទៅធ្វើរោងនោះ ពួកខ្លួនក៏បានបេះផ្លែស្វាយដែលដាំនៅក្នុងដីចម្ការខាងលើបានមួយកន្ត្រកផងដែរ និងបានយកផ្លែស្វាយទាំងនោះមកហូបជុំគ្នាផងដែរ។ ចំពោះមូលហេតុ ដែលខ្លួនហ៊ានបេះស្វាយទាំងនោះ ព្រោះមានការអនុញ្ញាតពីឈ្មោះ [redacted] អួន ដោយគាត់អះអាងថាជាចម្ការរបស់ឪពុកគាត់។ ក្រៅពីដើមស្វាយចម្ការខាងលើនោះ ក៏មានដាំដើមដំឡូងមីនៅតាមចន្លោះចម្ការស្វាយផងដែរ ប៉ុន្តែខ្លួនពុំមានឃើញមាននរណាទៅបំផ្លិចបំផ្លាញដើមដំឡូងមីទាំងនោះទេ។ ហើយការសាងសង់រោងខាងលើ ក៏មិនសង់នៅក្នុងដីដាំដើមដំឡូងមីនោះដែរ ពោលគឺសង់នៅលើដីទំនេរប៉ុណ្ណោះ។ ខ្លួនក៏សូមបញ្ជាក់ផងដែរថា: កន្លងមកឈ្មោះ [redacted] អួន និងប្រពន្ធឈ្មោះ [redacted] មុំ ក៏ធ្លាប់ប្រុងនឹងយកឡាន



Scanned with CamScanner

ទៅបេះយកផ្លែស្វាយនៅក្នុងដីចម្ការនោះដែរ ប៉ុន្តែត្រូវបានឈ្មោះ [redacted] សារ៉ែម បានមកហាមឃាត់ទាន់ និងបានអះអាងថា: ដីចម្ការខាងលើនោះ គឺជាដីកម្មសិទ្ធិរបស់គាត់ ដោយអះអាងបន្ថែមថា: គាត់បានទិញដីខាងលើពីឈ្មោ[redacted] សុវណ្ណា ត្រូវជាប្រពន្ធក្រោយ របស់ឈ្មោះ [redacted] ឡាយ (ឪពុករបស់ឈ្មោះ [redacted] អូន) រួចហើយ។ ចំពោះដីនេះ ខ្លួន និងប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] គីមអៀង ពុំមានចេតនាចង់បានដីចម្ការខាងលើនោះទេ ពីព្រោះដីខាងលើមិនមែនជាទ្រព្យសម្បត្តិរបស់ពួកខ្លួន។ ចំពោះដីនេះគឺជាទ្រព្យក្រោយអាពាហ៍ពិពាហ៍រវាងឈ្មោះ [redacted] សុវណ្ណា និងឈ្មោះ [redacted] ឡាយ ដែលត្រូវជាឪពុកក្មេក។ សូមបញ្ជាក់បន្ថែមថា: ក្រោយពីធ្វើរោងនៅលើដីចម្ការនោះរួចមក នៅក្នុងអំឡុងខែមេសា ឆ្នាំ២០២៣ ឈ្មោះ [redacted] មុំ ពិតជាធ្លាប់បានទៅហាមឃាត់ មិនឱ្យឡានរបស់ឈ្មោះ [redacted] សារ៉ែម ចូលទៅប្រមូលផលផ្លែស្វាយនៅលើដីចម្ការនោះប្រាកដមែន។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ **ឡូត គីមអៀង** បានឆ្លើយនៅក្នុងដំណាក់កាលនៃនីតិវិធីថា៖ ខ្លួនមិនទទួលស្គាល់ការចោទប្រកាន់របស់តំណាងអយ្យការទេ ព្រោះខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះឡើយ។ ខ្លួនសូមបញ្ជាក់ថា: កន្លងមកខ្លួនពុំដែលដឹងថាឪពុករបស់ខ្លួនឈ្មោះ [redacted] ឡាយ មានដីស្ថិតនៅភូមិភ្នំប្រាថ់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ នោះទេ។ ចំពោះការចោទប្រកាន់មកលើរូបខ្លួន និងឈ្មោះ ស្វាយ អូន (ត្រូវជាបងប្រុសរបស់ខ្លួន) ,ឈ្មោះ [redacted] មុំ (បងថ្លៃរបស់ខ្លួន) និងឈ្មោះ [redacted] ភាព (ប្ដីរបស់ខ្លួន) ថា បានចូលទៅរារាំងហាមឃាត់មិនឱ្យឈ្មោះ [redacted] សារ៉ែម និងប្ដីចូលទៅចម្ការខាងលើ ដើម្បីចូលទៅបេះស្វាយនោះ គឺ ខ្លួនពុំទទួលស្គាល់នោះដែរ ព្រោះថា: នៅថ្ងៃ០៤ និងទី០៦ ខែមីនា ឆ្នាំ ២០២៣ ដែលជាថ្ងៃកើតហេតុ គឺខ្លួនកំពុងតែស្នាក់នៅក្នុងខេត្តកំពង់ចាមនៅឡើយ ពោលគឺមិនបាននៅខេត្តកំពង់ធំនោះទេ។ ហេតុនេះការចោទប្រកាន់មកលើខ្លួនខាងលើ គឺខុសទាំងស្រុង។ ចំពោះសកម្មភាពរបស់ឈ្មោះ [redacted] អូន ,ឈ្មោះ [redacted] មុំ និងឈ្មោះ [redacted] ភាព គឺខ្លួនមិនបានដឹងទេ ហើយក៏មិនពាក់ព័ន្ធនឹងខ្លួននោះដែរ។ ហេតុនេះខ្លួនសូមសំណូមពរមកតុលាការមេត្តាសម្រេចឱ្យខ្លួនរួចផុត ពីបទចោទប្រកាន់ផងចុះ។

-តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **មុំ** បានឆ្លើយនៅក្នុងដំណាក់កាលនៃនីតិវិធីថា៖ កាលពីថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០២៣ ប្ដីរបស់ខ្លួនឈ្មោះ [redacted] អូន និងប្អូនប្រុសរបស់គាត់ឈ្មោះ [redacted] ភាព បានទៅជួយសង់រោងនៅក្នុងដីចម្ការរបស់គាត់មួយកន្លែង មានទីតាំងស្ថិតនៅក្នុងភ្នំប្រាថ់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដូចនេះខ្លួនមិនបានដឹងថា: ពួកគាត់ត្រូសត្រាយទាំងដើមដំឡូងមីរបស់ឈ្មោះ [redacted] សារ៉ែម ឬអត់ឡើយ តែប្ដីរបស់ខ្លួនបានប្រាប់ថា: គាត់ធ្វើរោងនៅកន្លែងស្រឡះតែប៉ុណ្ណោះ។ មូលហេតុដែលមានការចូលទៅកាន់កាប់ដីខាងលើ ពីព្រោះដោយសារជាដីកេរ្តិ៍របស់ឪពុកក្មេករបស់ខ្លួនឈ្មោះ [redacted] ឡាយ ជាមួយនឹងប្រពន្ធក្រោយរបស់គាត់ឈ្មោះ [redacted] សុវណ្ណា ហេតុដូចច្នេះ ដោយផ្អែកតាមផ្លូវច្បាប់ពួកខ្លួនជាកូនក៏ត្រូវទទួលបានចំណែកដែរ។ ខ្លួនសូមបញ្ជាក់ថា: បន្ទាប់ពីធ្វើរោងរួចមក គឺនៅក្នុងអំឡុងខែមេសា ឆ្នាំ២០២៣ ស្រាប់តែឈ្មោះ [redacted] សារ៉ែម បានឱ្យគេមកបេះផ្លែស្វាយនៅក្នុងចម្ការខាងលើ។ ខណៈពេលនោះដែរខ្លួនក៏បានហាមឃាត់មិនឱ្យពួកគាត់បេះផ្លែស្វាយទាំងនោះផងដែរ ដោយសារដីនេះមិនទាន់ដោះស្រាយគ្នាដាច់ស្រេច។ ម្យ៉ាងវិញទៀត មុនពេលខ្លួនឃាត់ពួកគាត់មិនឱ្យបេះស្វាយនោះ ក៏ព្រោះកន្លងទៅឈ្មោះ [redacted] សារ៉ែម និងពួកខ្លួនធ្លាប់ជួប និងបានដោះស្រាយគ្នានៅផ្ទះមេភូមិភ្នំព្រាក់ម្ដងរួចហើយផងដែរ ដោយកាលនោះឈ្មោះ [redacted] សារ៉ែម បាននិយាយថា: "ចំពោះចម្ការស្វាយទាំងនោះ បងឯងកុំបេះ គាត់ក៏កុំបេះ" ពោលគឺមិនអនុញ្ញាតឱ្យបេះរៀងៗខ្លួន។ ខ្លួនសូមបញ្ជាក់បន្ថែមថា: ពួកខ្លួនមិនមានលិខិតកាន់កាប់ ឬលិខិតបញ្ជាក់ពីកម្មសិទ្ធិលើដីនេះឡើយ។ ចំពោះការចូលទៅកាន់កាប់ដីចម្ការ និងសាងសង់រោងនោះ គឺមានឈ្មោះ [redacted] អូន ត្រូវជាប្ដីរបស់ខ្លួន, ឈ្មោះ [redacted] ភាព (ត្រូវជាប្អូនថ្លៃរបស់ខ្លួន) ,ឈ្មោះ [redacted] គីមអៀង (ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] ភាព) និងឈ្មោះ ពេជ្រ ត្រូវជាកូនប្រសាររបស់ឈ្មោះ [redacted] ភាព គឺជាអ្នកចូលទៅកាន់កាប់ និងសង់រោង។ ចំណែកខ្លួនពុំបានចូលរួមក្នុងហេតុការណ៍នោះទេ។

-តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារ៉ែម** បានឆ្លើយនៅក្នុងដំណាក់កាលនៃនីតិវិធីថា៖ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២២ ខ្លួនបានទិញដីចំការស្វាយកែវរមៀត ០១ កន្លែង មានទំហំ ៥៤៧៩០ ម៉ែត្រការ៉េ មានទីតាំងស្ថិតនៅភូមិភ្នំប្រាថ់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ពីឈ្មោះ [redacted] សុវណ្ណា ភេទស្រី អាយុប្រហែល ៤៣ឆ្នាំ រស់នៅភូមិកំពប់អំបិល ឃុំបឹងល្វា ស្រុកសន្ទុក ខេត្តកំពង់ធំ (ត្រូវជាប្រពន្ធរបស់ឈ្មោះ [redacted] ឡាយ) ក្នុងតម្លៃ ១៤.០០០ (មួយម៉ឺនបួន



Scanned with CamScanner

៣ន់) ដុល្លារអាមេរិក ដោយបានធ្វើជាលិខិតមានជាពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ និងលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២។ បន្ទាប់ពីខ្លួនបានទិញដីនេះរួចមក ខ្លួនបានចំណាយលុយប្រហែលជា ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ដើម្បីបាញ់សម្លាប់ស្មៅ និងថែទាំស្វាយកែវរមៀត ដែលមាននៅក្នុងដីចម្ការនោះ។ លុះដល់ពេលប្រមូលផលស្រាប់តែឈ្មោះ [redacted] អួន ភេទប្រុស ,ឈ្មោះ [redacted] មុំ ភេទស្រី ,ឈ្មោះ [redacted] ភាព ភេទប្រុស និងឈ្មោះ [redacted] គីមអៀង ភេទស្រី បានមកហាមឃាត់ខ្លួនមិនឱ្យប្រមូលផលឡើយ។ ក្រោយមកនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៣ ឈ្មោះ [redacted] ភាព ,ឈ្មោះ [redacted] គីមអៀង ,ឈ្មោះ [redacted] មុំ ,ឈ្មោះ [redacted] អួន និងបក្ខពួក បានចូលទៅបេះស្វាយនៅលើដីខាងលើ ដោយឃើញដឹកចេញប្រហែលជាង ០២ (ពីរ) បារ។ បន្ថែមពីនេះទៅទៀត នៅថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ លោក [redacted] គីមហុង ជាមេភូមិភ្នំប្រាច់បានប្រាប់ខ្លួនថា: ឈ្មោះ [redacted] អួន បានមកបង្ខាប់ឱ្យគាត់ធ្វើលិខិតនិរាករណ៍លើពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ និងលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ ផងដែរ ដោយបានបញ្ជាក់ថា: ដីខាងលើនេះ ឈ្មោះ [redacted] អួន បានដាក់ពាក្យបណ្ដឹងទៅសាលាឧទ្ធរណ៍ហើយ ប្រយ័ត្នជាប់ពាក់ព័ន្ធនឹងក្ដីក្ដាំនេះ។ ខ្លួនសូមបញ្ជាក់ថា: នៅក្នុងលិខិតបញ្ជាក់ប្រវត្តដីធ្លី ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ខ្លួនពិតជាបានបញ្ជាក់នៅក្នុងលិខិតខាងលើថា: បានកាន់កាប់ដីខាងលើតាំងពីឆ្នាំ២០១១ ប្រាកដមែន ដោយហេតុថា: ខាងធនាគារតម្រូវឱ្យបញ្ជាក់បែបនេះ បើពុំដូច្នោះទេ ខាងលើធនាគារនឹងមិនអនុញ្ញាតឱ្យផ្ដល់ប្រាក់កម្ចីឱ្យខ្លួននោះឡើយ។ ម្យ៉ាងវិញទៀត នៅក្នុងពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២២ ដែលធ្វើឡើងដោយមិនមានត្រាមេឃុំគឺដោយសារតែពេលនោះខាងធនាគារតម្រូវឱ្យខ្លួនគ្រាន់តែបញ្ជាក់ឱ្យបានច្បាស់ថា: ភាគីអ្នកលក់ដីឈ្មោះ [redacted] ឡាយ និងប្រពន្ធឈ្មោះ [redacted] សុវណ្ណា ពិតជាបានលក់ដីខាងលើឱ្យមកខ្លួន និងប្ដី គឺគ្រប់គ្រាន់ហើយ ដោយហេតុនេះហើយទើបខ្លួនពុំបានយកទៅឱ្យមេឃុំចុះហត្ថលេខា និងបោះត្រា។

## សេចក្តីសន្និដ្ឋានថ្លែងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការ៖ ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទក្នុងដំណាក់កាលនៃនីតិវិធី, តាមការស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងដំណាក់កាលនៃនីតិវិធី និងការពិនិត្យភស្តុតាងពាក់ព័ន្ធដែលមាននៅក្នុងសំណុំរឿងតំណាងអយ្យការយល់ឃើញថា៖ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ឈ្មោះ [redacted] មុំ ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **ភាព** ភេទប្រុស អាយុ៥៥ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" ប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១**។ ហេតុដូច្នេះ តំណាងអយ្យការសូមតម្កល់ការចោទប្រកាន់ដូចនៅក្នុងដីកាសន្និដ្ឋានស្ថាពរលេខ: **៤៧០/២០២៤** ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តកំពង់ធំ ដដែល។

## សេចក្តីសន្និដ្ឋានថ្លែងសុំរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

- មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូមគោរពអង្គសវនាការទាំងមូល ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **អួន** និងឈ្មោះ [redacted] មុំ ធ្វើការស្នើសុំដល់ចៅក្រមជំនុំជម្រះ ក៏ដូចជាតំណាងអយ្យការ ផ្អែកតាមកិច្ចពិភាក្សាដេញដោលចំពោះមុខ ខ្លួនសូមធ្វើការឆ្លើយតបចំពោះសំណុំរឿងព្រហ្មទណ្ឌលេខ ២៥១ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៣ ផ្អែកទៅតាមកិច្ចពិភាក្សាដេញដោល និងផ្អែកទៅតាមការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងឃើញថា: កូនក្ដីខ្លួនទាំងពីរនាក់ខាងលើ ពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការនោះទេ ដោយហេតុថា តាមចម្លើយក្នុងការដេញដោលនេះ ឃើញថា ឈ្មោះ [redacted] អួន ក្នុងស្ថានភាពជាក់ស្ដែងនេះ គឺជាជនពិការ ដូច្នេះគាត់មិនអាចទៅប្រព្រឹត្តអំពើហិង្សា ឬ ក៏ទៅកាប់បំផ្លាញទៅលើដំណាំមានស្វាយ និងដើមដំឡូងមី ដូចការចោទប្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ហើយផ្អែកទៅតាមចម្លើយរបស់ឈ្មោះ [redacted] អួន និងជនជាប់ចោទទាំងបីនាក់ទៀត ក៏មិនបានឆ្លើយថា: កូនក្ដីរបស់ខ្លួនទាំងពីរនាក់បានប្រព្រឹត្តដូចការចោទប្រកាន់នោះដែរ។ ចំពោះការសាងសង់រោងលើដីខាងលើនោះ គឺក្នុងគោលបំណងដោយគិតថា



Scanned with CamScanner

ដីខាងលើគឺជាទ្រព្យសម្បត្តិរបស់ឪពុករបស់កូនក្តីខ្លួនឈ្មោះ [redacted] ឡាយ ប៉ុណ្ណោះ។ មិនតែប៉ុណ្ណោះ ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាអែម បានឆ្លើយថា គាត់បានទិញដីខាងលើពីឈ្មោះ [redacted] សុវណ្ណា។ ហើយឈ្មោះ [redacted] សុវណ្ណា គឺត្រូវជាប្រពន្ធទី២ របស់ឈ្មោះ [redacted] ឡាយ ដែលត្រូវជាឪពុកកូនក្តីរបស់ខ្លួន ដូច្នេះដីខាងលើគឺជាទ្រព្យសម្បត្តិរួមរវាងឈ្មោះ [redacted] សុវណ្ណា និងឈ្មោះ [redacted] ឡាយ ដូច្នេះការចូលទៅកាន់កាប់ដីខាងលើ ពីសំណាក់កូនក្តីរបស់ខ្លួន និងមនុស្សទាំង៣នាក់ទៀតទៅលើដីខាងលើ គឺដោយគិតថា ជាដីឪពុករបស់គាត់ ហើយជាក់ស្តែងដីនោះ ពិតជាដីរបស់ឪពុករបស់ពួកគាត់មែន ព្រោះសាក្សីដែលសំខាន់ក្នុងការបញ្ជាក់នេះ គឺឈ្មោះ [redacted] សុវណ្ណា ដែលជាអ្នកលក់ដីខាងលើឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី បានទទួលស្គាល់ថា ដីខាងលើគឺជាដីដែលជាទ្រព្យសម្បត្តិរួមរបស់ឈ្មោះ [redacted] សុវណ្ណា និងឈ្មោះ [redacted] ឡាយ។ ដូច្នេះ ការចូលទៅកាន់កាប់ដីខាងលើ គឺក្នុងគោលបំណងទៅកាន់កាប់ដី ដែលជាទ្រព្យរបស់ឪពុករបស់ខ្លួនប៉ុណ្ណោះ និងមិនបានចូលទៅកាន់កាប់ដោយប្រើប្រាស់ហិង្សានោះឡើយ។ ម្យ៉ាងវិញទៀត ការចូលទៅសង់រោងក្នុងដីខាងលើ គឺធ្វើឡើងដោយមានការសុំអនុញ្ញាតពីមេភូមិផងដែរ ដើម្បីធ្វើការការពារការឆេះភ្លើងព្រៃ ពីដីរបស់គាត់ ចូលទៅក្នុងចម្ការកៅស៊ូរបស់ក្រុមហ៊ុននៅក្បែរនោះ។ ដូច្នេះចំពោះអំពើដែលចូលទៅកាន់កាប់ដីនៅទីនោះ គឺមិនមានចេតនាប្រព្រឹត្តអំពីហិង្សាទៅលើអ្នកកាន់កាប់អចនវត្ថុដោយសុចរិតនោះទេ។ ហេតុដូច្នេះផ្អែកតាមក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ កាលណាអំពើណាមួយ ដែលមិនមែនជាបទល្មើសទេ គប្បីឱ្យចៅក្រមជំនុំជម្រះសម្រេចឱ្យជនជាប់ចោទ រួចផុតពីបទចោទ។ ចំពោះសំណងរដ្ឋប្បវេណីរបស់ដើមបណ្តឹងសូមឱ្យតុលាការសម្រេចដោយឆន្ទានុសិទ្ធិចុះ។ សរុបមកខ្លួនសូមសន្និដ្ឋានថា សូមឱ្យតុលាការមេត្តាសម្រេចឱ្យកូនក្តីរបស់ខ្លួនរួចខ្លួនពីបទចោទពីបទ: ហិង្សាដោយចេតនាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ចាប់ពីពេលនេះតទៅ។

-លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **គឹមអៀង** និងឈ្មោះ [redacted] **ភាព** បានធ្វើសេចក្តីសន្និដ្ឋានថា៖ សូមគោរពអង្គសវនាការទាំងមូល ខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] **គឹមអៀង** និងឈ្មោះ [redacted] **ភាព** ធ្វើការស្នើសុំដល់ចៅក្រមជំនុំជម្រះ ក៏ដូចជាតំណាងអយ្យការ ខ្លួនសូមឯកភាពចំពោះការធ្វើការសន្និដ្ឋានរបស់សហភាតា ដែលបានធ្វើសេចក្តីសន្និដ្ឋានការពារកូនក្តីរបស់ខ្លួនផងដែរ ឃើញថា កូនក្តីរបស់ខ្លួនឈ្មោះ [redacted] ភាព និងប្រពន្ធឈ្មោះ ឡូត គឹមអៀង ,ឈ្មោះ [redacted] អួន និងប្រពន្ធឈ្មោះ [redacted] មុំ បានទទួលរងនូវការចោទប្រកាន់ពីបទ: “ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត” តាមមាត្រា២៥៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ប្រព្រឹត្តកាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ នៅភូមិភ្នំច្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១៨០ អ.ក/២០២៣ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ធំ ដោយមានឈ្មោះ [redacted] សាអែម និងប្តីឈ្មោះ [redacted] ទិត អះអាងថា: ខ្លួនបានទិញដីចំការស្វាយកែវរមៀតមួយកន្លែង មានទំហំ ៤៤៧៩០ ម៉ែត្រក្រឡា ពីឈ្មោះ [redacted] សុវណ្ណា កាលពីឆ្នាំ២០២២ ដោយផ្អែកលើ ពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ របស់មេភូមិភ្នំច្រាច់ និងលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ របស់មេឃុំក្រយា។ក្នុងអង្គហេតុនេះ ពុំមានភស្តុតាង ឬ សាក្សីណាម្នាក់អាចបញ្ជាក់ថាឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] គឹមអៀង ឬ ជនជាប់ចោទផ្សេងទៀតបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់នោះឡើយ។ ក្នុងអង្គហេតុនេះ មានភស្តុតាងមួយចំនួនដែលអាចបញ្ជាក់អំពីអត្ថិភាពនៃអង្គហេតុដូចជា៖ ពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៩/០៩/២០២២ របស់មេភូមិភ្នំច្រាច់, លិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី២២/០៩/២០២២ របស់មេឃុំក្រយា ,លិខិតបញ្ជាក់ផ្ទេរលក់ដី ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១១ របស់មេឃុំក្រយា ,កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់សាក្សីឈ្មោះ [redacted] សុវណ្ណា ,កំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២៨/០៤/២០២៣ របស់ដើមបណ្តឹងឈ្មោះ [redacted] សាអែម។ ផ្អែកតាមកំណត់ហេតុស្រង់ចម្លើយ ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាអែម បានអះអាងថាខ្លួនបានទិញដីចំការខាងលើពីឈ្មោះ [redacted] សុវណ្ណា នៅក្នុងឆ្នាំ២០២២ ប៉ុន្តែខ្លួនបានចូលទៅកាន់កាប់ និងអាស្រ័យផលលើដីទំនាស់នេះតាំងពីឆ្នាំ២០១១ មកម្ល៉េះ។ ផ្ទុយទៅវិញ នៅដំណាក់កាលជំនុំជម្រះកាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ឈ្មោះ [redacted] សាអែម បានទទួលស្គាល់ថាខ្លួនបានទិញដីខាងលើនៅឆ្នាំ២០២២ ហើយបានចូលកាន់កាប់ និងអាស្រ័យផល ក៏នៅឆ្នាំ២០២២ដែរ មិនមែនក្នុងឆ្នាំ២០១១ ដូចបានរៀបរាប់ក្នុងលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី



Scanned with CamScanner

២២ ខែកញ្ញា ឆ្នាំ២០២២ ចេញដោយមេឃុំក្រយា។ លិខិតបញ្ជាក់ប្រវត្តិដីធ្លីខាងលើជាឯកសារ ក្លែងក្លាយធ្វើឡើងដើម្បីទទួលបានកម្ចីពីធនាគារអេស៊ីលីដា (ACLEDA) តែប៉ុណ្ណោះ ដែលចំណុចនេះ ស្តែងឱ្យឃើញថា: ការកាន់កាប់លើដីទំនាស់ទើបតែមានរយៈពេលជិត ០២ ឆ្នាំប៉ុណ្ណោះ នៅមិនទាន់បំពេញតាមលក្ខខណ្ឌនៃការធ្វើលទ្ធកម្មនៃកម្មសិទ្ធិស្របតាមមាត្រា១៦២ នៃក្រមរដ្ឋប្បវេណីឡើយ។ ពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ គ្រាន់តែជាឯកសារចេញដោយមេភូមិភ្នំប្រាច់ពុំមានហត្ថលេខា និងត្រាពីមេឃុំក្រយាឡើយ ដែលស្តែងឱ្យឃើញថា: លិខិតខាងលើមិនមានតម្លៃជាលិខិតយថាភូតដោយស្របតាមមាត្រា៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឡើយ។ ចំណុចទាំងពីរខាងលើបញ្ជាក់ឱ្យឃើញថា: ឈ្មោះ [redacted] សារ៉ែម និងប្តីឈ្មោះ [redacted] ទិត មិនទាន់ ក្លាយជាភោគៈសុចរិត ដែលមានលក្ខខណ្ឌតតាំងតាមច្បាប់សារធាតុឡើយ។ យោងតាមពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០២៣ កំណត់ហេតុស្រង់ចម្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលស៊ើបសួរឈ្មោះ [redacted] សារ៉ែម បានចោទប្រកាន់ថា ជនជាប់ចោទទាំង ០៤ នាក់ ឈ្មោះ [redacted] ភាព និងប្រពន្ធឈ្មោះ [redacted] គីមអៀង ,ឈ្មោះ [redacted] អូន និងប្រពន្ធឈ្មោះ [redacted] មុំ បានចូលទៅក្នុងដីចំការស្វាយរបស់ខ្លួនសង់រោង និងបំផ្លាញដំណាំ និងលួចបេះផ្លែស្វាយរបស់ខ្លួនប៉ុន្តែនៅដំណាក់កាលជំនុំជម្រះកាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ ឈ្មោះ [redacted] សារ៉ែម បានទទួលស្គាល់ថា ពុំមានសាក្សីណាម្នាក់បានឃើញឈ្មោះ [redacted] គីមអៀង និងឈ្មោះ [redacted] មុំ មានវត្តមាននៅ កន្លែងកើតហេតុឡើយ ដែលចម្លើយនេះមានភាពស៊ីសង្វាក់ទៅនឹងចម្លើយរបស់ ឈ្មោះ [redacted] សុវណ្ណា ដែលឆ្លើយបំភ្លឺថាខ្លួនដឹងអង្គហេតុនេះពីឈ្មោះ [redacted] សារ៉ែម ប៉ុណ្ណោះ។ ដូច្នេះចម្លើយរបស់ឈ្មោះ [redacted] សារ៉ែម និងសាក្សីឈ្មោះ [redacted] សុវណ្ណា មិនមានតម្លៃជាភស្តុតាងដាក់បន្ទុកឡើយ ដោយសារតែឈ្មោះ [redacted] សារ៉ែម បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួចហើយ ដោយស្របតាមមាត្រា៣១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចត្រូវបានគេស្តាប់ចម្លើយក្នុងឋានៈជា សាក្សីបានទេ" ,មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញចែងថា "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ" និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា "វិមតិសង្ស័យត្រូវតែជាអត្ថប្រយោជន៍ ដល់ជនជាប់ចោទជានិច្ច" ផ្អែកតាមកំណត់ហេតុស្រង់ចម្លើយសាក្សី ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២៣ ឈ្មោះ [redacted] សុវណ្ណា បានឆ្លើយបំភ្លឺថា ខ្លួន និងប្តីឈ្មោះ [redacted] ឡាយ ត្រូវជាឪពុកបង្កើតរបស់ឈ្មោះ [redacted] អូន និងឈ្មោះ [redacted] គីមអៀង និងត្រូវជាឪពុកក្មេករបស់ឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] មុំ មានដីរួមគ្នាក្រោយអាពាហ៍ពិពាហ៍(ទ្រព្យសម្បត្តិរួម) ហើយឈ្មោះ [redacted] ឡាយ បានទទួលមរណៈភាពនៅ ក្នុងឆ្នាំ២០១១ ទើបខ្លួនសម្រេចលើកដីនេះឱ្យឈ្មោះ [redacted] សារ៉ែម ។ ដូច្នេះសបញ្ជាក់ឱ្យឃើញថា: ឈ្មោះ [redacted] អូន និងឈ្មោះ [redacted] គីមអៀង គឺជាសហសន្តតិជនលំដាប់ទី១ ដែលមានសិទ្ធិទាមទារឱ្យបែងចែកចំណែកជាមួយឈ្មោះ [redacted] សុវណ្ណា ដែលជាសន្តតិជនជានិច្ច ស្របតាមមាត្រា៣២៦ ,មាត្រា១១៤៥ ,មាត្រា១១៤៧ ,មាត្រា១១៥៦ ,មាត្រា១១៦១ នៃក្រមរដ្ឋប្បវេណី។ សរុបមកឃើញថា ពុំមានធាតុផ្សំនីត្យានុកូល នៅក្នុងអំពើហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ដូចការចោទប្រកាន់របស់តំណាងអយ្យការឡើយ ដោយយោងលើមូលហេតុ ជនជាប់ចោទទាំងបួនរូបខាងលើ ជាសហសន្តតិជនរបស់មត៌កជនឈ្មោះ [redacted] ឡាយ និងត្រូវបានចាត់ទុកថា ជាសហកម្មសិទ្ធិករលើដីនេះផងដែរ។ ដូច្នេះ ការចូលទៅទីតាំងកើតហេតុ ដើម្បីសង់រោង និងធ្វើសកម្មភាពផ្សេងៗមិនមែនជាបទល្មើសឡើយ និងពាក្យសុំផ្ទេរសិទ្ធិកាន់កាប់ដី ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២ របស់មេភូមិភ្នំប្រាច់ មិនមានតម្លៃជាលិខិតយថាភូតទេ ហើយលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ របស់មេឃុំក្រយា គឺជាឯកសារក្លែងក្លាយ ហើយឯកសារក៏មិនមានតម្លៃជាភស្តុតាងដាក់បន្ទុកដែរ។ ហេតុនេះ ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដូចការចោទប្រកាន់ដោយផ្អែកលើគោលការណ៍គ្មានបទល្មើស គ្មានទោស បើគ្មានច្បាប់ចែង ឬ ស្របតាមមាត្រា ៣ នៃក្រមព្រហ្មទណ្ឌចែងថា "មានតែអំពើបង្កើតជាបទល្មើស នៅពេលដែលអំពើនោះមានចែងក្នុងបញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌបាន។ មានតែទោសដែលមាន ចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមាននៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបអាចត្រូវប្រកាសបាន។ ជាចុងក្រោយ តាងនាមជាមេធាវីការពារសិទ្ធិ ខ្លួនសូមសំណូមពរដល់អង្គសវនាការ សម្រេចឈ្មោះ [redacted] ភាព និងឈ្មោះ [redacted] គីមអៀង រួចផុតបទចោទពីបទហិង្សាលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ដោយស្របទៅតាមមាត្រា៣៥០ នៃក្រមនីតិវិធីព្រហ្ម



Scanned with CamScanner

ទណ្ឌចាប់ពីពេលនេះតទៅ។ សេចក្តីដូចបានជម្រាបជូនខាងលើ សូមអង្គសវនាការ មេត្តាទទួលសំណើរបស់យើងខ្ញុំដោយក្តីអនុគ្រោះ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

ជនជាប់ចោទឈ្មោះ [redacted] **ភាព** ,ឈ្មោះ [redacted] **អួន** និងឈ្មោះ [redacted] **គីមអៀង**, សំណូមពរតុលាការសម្រេចឱ្យពួកខ្លួនទាំងបួននាក់រួចផុតពីបទចោទ។

-ក្រោយពីបានដំណើរការកិច្ចពិភាក្សាដេញដោលនាសវនាការ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **មុំ**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ភាព**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **អួន**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **គីមអៀង**

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារ៉ែម**

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យភស្តុតាងឯកសារនានាក្នុងសំណុំរឿង និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

**សំអាងហេតុ**

**-យល់ឃើញថា:** តាមដីកាដំណោះស្រាយលេខ: **៤១២០/២០២៣** ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ធំ ដែលសម្រេចបញ្ជូនជនត្រូវចោទឈ្មោះ [redacted] **មុំ** ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ, ឈ្មោះ [redacted] **ភាព** ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ ជាប់ចោទពីបទ "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" ប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១**។

**-យល់ឃើញថា:** តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ភាព** ,ឈ្មោះ [redacted] **អួន** ,ឈ្មោះ [redacted] **គីមអៀង** នៅក្នុងដំណាក់កាលនីតិវិធី និងតាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **មុំ** នៅក្នុងដំណាក់កាលស៊ើបសួរ ,តាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារ៉ែម** នៅក្នុងដំណាក់កាលនីតិវិធី ,រួមទាំងការពិនិត្យភស្តុតាងជាឯកសារនៅក្នុងសំណុំរឿង និងវត្ថុតាងពាក់ព័ន្ធ អាចឱ្យតុលាការជឿជាក់បានថា: កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ស្ថិតនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ពិតជាមានអង្គហេតុនៃបទល្មើស "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" ប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] **មុំ** ភេទស្រី អាយុ ៦១ ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **ភាព** ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ ដូចការចោទប្រកាន់របស់តំណាងអយ្យការមែន។

**-យល់ឃើញថា:** យោងតាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាលឆ្នាំ២០០១** ជនណាប្រើអំពើហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត ទោះជាមិនទាន់បានធ្វើប័ណ្ណ ឬកំពុងមានទំនាស់ក៏ដោយ ត្រូវបានកំណត់ថា "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**"។

**-យល់ឃើញថា:** អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] **មុំ**, ឈ្មោះ [redacted] **ភាព**, ឈ្មោះ [redacted] **អួន** និងឈ្មោះ [redacted] **គីមអៀង** ដែលបានធ្វើសកម្មភាព រារាំងឈ្មោះ [redacted] **សារ៉ែម** និងប្តីឈ្មោះ [redacted] **ទិត** មិនឱ្យចូលទៅប្រមូលផលផ្លែស្វាយនៅលើដីចម្ការរបស់ពួកគេ ដែលបានទិញពីពីឈ្មោះ [redacted] **សុវណ្ណា** ដោយបានធ្វើជាលិខិតពាក្យសុំផ្ទេរសិទ្ធិដី ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ

២០២២ និងលិខិតបញ្ជាក់ប្រវត្តិដីធ្លីលេខ: ៣៦៣២ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២២ ទទួលស្គាល់ដោយភូមិឃុំ ត្រូវបានកំណត់ថា: ជា "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**"។

**-យល់ឃើញថា:** ជនជាប់ចោទឈ្មោះ [redacted] មុំ, ឈ្មោះ [redacted] ភាព, ឈ្មោះ [redacted] **អួន** និងឈ្មោះ [redacted] **គីមអៀង** ជានីតិជន និងមិនមានភស្តុតាង ឬសញ្ញាណណាដែលបញ្ជាក់ថា: ជននេះមានវិបល្លាសស្មារតីទេ ហេតុដូច្នេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួន។ អំពើរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ សន្តិសុខ និងរបៀបរៀបរយក្នុងសង្គម។

**-យល់ឃើញថា:** មានភស្តុតាងដាក់បន្ទុក និងមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដែលបង្ហាញឱ្យឃើញពីពិរុទ្ធភាពលើជនជាប់ចោទ ដែលអាចឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] មុំ ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ , ឈ្មោះ [redacted] ភាព ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ ពីបទ "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" តាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១** ដែលបានប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣។

**-យល់ឃើញថា:** តំណាងអយ្យការប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] មុំ ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] ភាព ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ ពីបទ "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" តាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១** ដែលបានប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ គប្បីតុលាការពិចារណា។

**-យល់ឃើញថា:** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានសន្និដ្ឋាននាពេលសវនាការថា៖ ស្នើសុំឱ្យតុលាការសម្រេចឱ្យកូនក្តីរបស់ខ្លួនឈ្មោះ [redacted] មុំ ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **ភាព** ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ រួចខ្លួនពីបទ: "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" តាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១** ដែលបានប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ព្រោះបើផ្អែកតាមពីបទ "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" តាមបញ្ញត្តិមាត្រា**២៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១** ដែលបានប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាច់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣ ពីព្រោះពុំមានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ក្នុងការកំណត់ថាកូនក្តីរបស់ខ្លួនមានទោសនោះឡើយ។ គប្បីតុលាការពិចារណា។

**-យល់ឃើញថា:** ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សារ៉ែម** បានទាមទារសំណងការខូចខាតសរុបចំនួន **២.០០០ (ពីរពាន់) ដុល្លារអាមេរិក** ពីជនជាប់ចោទឈ្មោះ [redacted] មុំ ,ឈ្មោះ [redacted] **ភាព** ,ឈ្មោះ [redacted] **អួន** និងឈ្មោះ [redacted] **គីមអៀង**។ គប្បីតុលាការពិនិត្យ និងសម្រេច។

**-យល់ឃើញថា:** ជនជាប់ចោទឈ្មោះ [redacted] មុំ ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **ភាព** ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ និងឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ សំណូមពរតុលាការមេត្តាសម្រេចឱ្យពួកខ្លួន រួចខ្លួនពីបទ: ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត។

## <u>ហេតុដូច្នេះសម្រេច</u>

**<u>១/-ផ្តន្ទាទោស៖</u>**

**១.១**-ឈ្មោះ [redacted] **មុំ** ភេទស្រី អាយុ៦១ឆ្នាំ ជាតិខ្មែរ (សាវតារជាតិខាងលើ) "ក្រៅឃុំ"

**១.២**-ឈ្មោះ [redacted] **ភាព** ភេទប្រុស អាយុ៥៤ឆ្នាំ ជាតិខ្មែរ (សាវតារជាតិខាងលើ) "ក្រៅឃុំ"

**១.៣**-ឈ្មោះ [redacted] **អួន** ភេទប្រុស អាយុ៥៩ឆ្នាំ ជាតិខ្មែរ (សាវតារជាតិខាងលើ) "ក្រៅឃុំ"

**១.៤**-ឈ្មោះ [redacted] **គីមអៀង** ភេទស្រី អាយុ៥៣ឆ្នាំ ជាតិខ្មែរ (សាវតារជាតិខាងលើ) "ក្រៅឃុំ"



Scanned with CamScanner

ដាក់ពន្ធនាគាម្នាក់ៗក្នុង កំណត់រយៈពេល **០៦ (ប្រាំមួយ) ខែ** តែទោសនេះត្រូវ (**ព្យួរ**) តាមបញ្ញត្តិមាត្រា **១០៦** និងមាត្រា**១០៧** នៃក្រមព្រហ្មទណ្ឌ ពីបទ "**ហិង្សាទៅលើអ្នកកាន់កាប់អចលនវត្ថុដោយសុចរិត**" តាមបញ្ញត្តិមាត្រា២៥៣ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ប្រព្រឹត្តនៅចំណុចភូមិភ្នំប្រាថ់ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ កាលពីថ្ងៃទី០៤ និងថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៣។

២/-បង្គាប់ឱ្យឈ្មោះ [redacted] **តាត** ,ឈ្មោះ [redacted] **អូន** ,ឈ្មោះ [redacted] **គីមអៀង** និងឈ្មោះ [redacted] **មុំ** រួមគ្នាសងសំណងការខូចខាតចំនួន **២.000.000 (ពីរលាន) រៀល** ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាអែម**។ ការទាមទារលើសពីនេះត្រូវបដិសេធចោល។

-សាលក្រមនេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី**២៧** ខែ**កុម្ភៈ** ឆ្នាំ**២០២៤** និងប្រកាសជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ នៅថ្ងៃទី**១២** ខែ**មីនា** ឆ្នាំ**២០២៤** ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **តាត**, ឈ្មោះ [redacted] **អូន** និងឈ្មោះ [redacted] **គីមអៀង** និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សាអែម** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **មុំ** ។

-ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមជំនុំជម្រះ** |
|---|---|
| ហត្ថលេខា និងត្រា: [redacted] | ហត្ថលេខា និងត្រា: [redacted] |

| | |
|---|---|
| **បានឃើញ** | "**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**" |
| កំពង់ធំ, ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤ | ថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ |
| **ចៅក្រមជំនុំជម្រះ** | កំពង់ធំ, ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៤ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |



Scanned with CamScanner